# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## កម្រងជីវប្រវត្តិសហគមន៍ និងសកម្មជនក្នុងទំនាស់ដីធ្លី

ទិដ្ឋភាពនៃការរំលោភយកដី ៖ កម្រងជីវប្រវត្តិដីធ្លី

### អ្នកភូមិក្បាលរមាស ខេត្តស្ទឹងត្រែង ៖ ទំនប់វារីអគ្គិសនីសេសានក្រោម ២ គំរាមកំហែងសហគមន៍ជនជាតិដើមភាគតិច



ភូមិក្បាលរមាសគឺជាភូមិមួយក្នុងចំណោមភូមិមួយចំនួនរបស់អ្នកភូមិជនជាតិដើមភាគតិចដែលនឹងត្រូវជន់លិចដោយសារអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលបច្ចុប្បន្នឋិតនៅកំពុងសាងសង់ដោយក្រុមហ៊ុនផលិតថាមពលអគ្គិសនីសេសាន ក្រោម២។ ទីស្តីការគណៈរដ្ឋមន្ត្រីបានសម្រេចយល់ព្រមលើគម្រោងនោះក្នុងខែ វិច្ឆិកា ឆ្នាំ ២០១២ ទោះជាការសិក្សាពីផលប៉ះពាល់បរិស្ថានពុំបានអនុវត្តត្រូវទៅនឹងស្តង់ដាអន្តរជាតិក៏ដោយ។ ការកសាងទំនប់វារីអគ្គិសនីនេះបានចាប់ផ្តើមនៅខែកុម្ភៈ ឆ្នាំ២០១៤ និងសង្ឃឹមថានឹងរួចរាល់នៅឆ្នាំ២០១៧។ អ្នកភូមិត្រូវបានផ្តល់ដីដែលមានទំហំតូចនៅកន្លែងតាំងលំនៅថ្មី រួមមានទាំងសំណងមួយចំនួន ប៉ុន្តែអ្នកភូមិភាគច្រើនបានបដិសេធបោះបង់ចោលលំនៅឋាននិងដីបុព្វបុរសរបស់ពួកគេ។ នៅខែមេសា ឆ្នាំ២០១៦ អាជ្ញាធរខេត្តបានប្រកាសថា អាជ្ញាធរនឹងមិនទទួលខុសត្រូវចំពោះអ្វីដែលនឹងកើតឡើងចំពោះអ្នកភូមិណាដែលមិនព្រមទទួលសំណងនោះទៀតទេទោះជាដល់ថ្នាក់បាត់បង់ជីវិតក៏ដោយ។

### អ្នកភូមិប្រមេរុ ខេត្តព្រះវិហារ ៖ សហគមន៍ជនជាតិដើមភាគតិច រងការគំរាមកំហែងដោយក្រុមហ៊ុនចម្ការអំពៅរបស់ជនជាតិចិន

ជនជាតិដើមភាគតិចគួយបានរស់នៅលើដីរបស់ខ្លួននៅឃុំប្រមេរុ តាំងពីជំនាន់បុព្វបុរសរបស់ពួកគាត់មក។ ក្នុងខែកក្កដា ឆ្នាំ២០១១ ដីទំហំ១៧.៨៥៦ ហិកតាក្នុងឃុំប្រមេរុនិងឃុំក្បែរៗនោះត្រូវបានធ្វើអនុបយោគឱ្យក្លាយទៅជាដីឯកជនរបស់រដ្ឋ និង បានផ្តល់ទៅឱ្យក្រុមហ៊ុនឡានហ្វេង និងក្រុមហ៊ុនរួយហ្វេងដែលក្រុមហ៊ុនទាំងពីរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបណ្តុំ ក្រុមហ៊ុន ស្ករចិន ដែលទទួលបានសម្បទានដីសេដ្ឋកិច្ចក្នុងទំហំសរុបចំនួន ៤០.០០០ ហិកតា។ នៅក្នុងខែមេសា ឆ្នាំ២០១២ ក្រុមហ៊ុនចិន ទាំងពីរបានចាប់ផ្តើមឈូសឆាយដីកសិកម្ម និងព្រៃអារក្សរបស់សហគមន៍។ តំណាងក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋានបានគំរាមរកបាញ់ និងចង់ចាប់ខ្លួនសមាជិកសហគមន៍ក្នុងពេលដែលពួកគាត់ធ្វើការតវ៉ា។ សហគមន៍កំពុងស្ថិតនៅក្នុងដំណើរការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព ដើម្បីផ្តល់ការការពារផ្លូវច្បាប់ទៅលើដីជនជាតិដើមភាគតិចរបស់ពួកគាត់តាមច្បាប់កម្ពុជា។



### ខេត្តសៀមរាប ៖ អ្នកភូមិតានីកំពុងមានជម្លោះដីធ្លីជាមួយអាជ្ញាធរអប្សរា



ក្នុងឆ្នាំ២០០៦ អាជ្ញាធរអប្សរា ដែលទទួលខុសត្រូវក្នុងការការពារឧទ្យានបុរាណវិទ្យាអង្គរវត្ត បានព្យាយាមបញ្ចុះបញ្ចូលអ្នកភូមិឱ្យលក់ដីកសិកម្មរបស់ខ្លួនឱ្យទៅពួកគេ។ អាជ្ញាធរអប្សរា មានបំណងបង្កើត "ភូមិធម្មជាតិ" មួយ នៅលើផ្ទៃដី ១.០១២ ហិកតា ដើម្បីផ្តល់ផ្ទះសម្បែងដល់អ្នករស់នៅក្នុងតំបន់មិនរៀបរយមួយចំនួន ដែលមកពីតំបន់ជុំវិញនោះ។ ក្នុងអំឡុងពេលចរចា អាជ្ញាធរអប្សរាបានបញ្ចុះបញ្ចូលឱ្យគ្រួសារជាច្រើនផ្តិតមេដៃលើឯកសារលក់ដីហើយបន្ទាប់មកបានផ្តល់សំណងដល់អ្នកភូមិតិចជាងចំនួនដែលបានព្រមព្រៀងគ្នា។ ពលរដ្ឋចំនួន ៣៨ គ្រួសារមិនព្រមលក់ដីទាំងនោះទេដោយសារតែពួកគាត់ចង់បានដីត្រឡប់មកវិញឬដីជាថ្នូរដើម្បីឱ្យពួកគាត់អាចបន្តដាំស្រូវទៅទៀតបាន។ ទោះបីជាគ្រួសារទាំងអស់មិនយល់ព្រមលក់ដីក៏ដោយ ក៏អាជ្ញាធរអប្សរាបានបង្កើតព្រំប្រទល់មួយនៅជុំវិញដីរបស់អ្នកភូមិដើម្បីយកដីទាំងនោះ។ គ្រួសារទាំងនោះក៏បានទទួលរងការធ្វើទុក្ខបុកម្នេញតាមផ្លូវតុលាការបន្ទាប់ពីអាជ្ញាធរអប្សរាបានដាក់ពាក្យបណ្តឹងមួយប្រឆាំងនឹងពួកគាត់ពីបទ "កាន់កាន់ដីរដ្ឋដោយខុសច្បាប់"។

### អ្នកស្រី កែវ សុភី អ្នកភូមិតាពេន ខេត្តសៀមរាប ៖ ការរំលោភយកដីពីសំណាក់រដ្ឋអំណាច

ក្នុងឆ្នាំ២០០២ អាជ្ញាធរខេត្តបានជូនដំណឹងថា ដីដែលពលរដ្ឋចំនួន ៩០ គ្រួសារបានដាំដំណាំនៅក្នុងភូមិ តាពេន ចាប់តាំង ពីឆ្នាំ១៩៩៧ មកនោះ គឺជាដីរបស់ឧទ្យានជាតិភ្នំគូលែន។ បន្ទាប់ពីមានសេចក្តីសម្រេចនេះ អ្នកភូមិត្រូវបានចោទថាកាន់កាប់ដីដោយខុសច្បាប់និងត្រូវបានទាហាន និងអាជ្ញាធរមូលដ្ឋានរឹបអូសយកដីរបស់ពួកគាត់ក្នុងឆ្នាំ២០០៣។ បន្ទាប់ពីការតវ៉ារបស់អ្នកភូមិអស់រយៈពេលជាច្រើនឆ្នាំក្នុងឆ្នាំ២០១៣ អាជ្ញាធរខេត្តបានប្រគល់ដីកសិកម្មជាង ៩០ ហិកតា ដល់អ្នកភូមិដែលជាទំហំតិចជាងពាក់កណ្តាលនៃទំហំដី ១៨៣ ហិកតាដែលពួកគាត់បានកាន់កាប់តាំងពីដើមមក។ ទោះជាយ៉ាងណារហូតមកដល់បច្ចុប្បន្នពួកគាត់នៅមិនទាន់ទទួលបានការចេញប័ណ្ណកម្មសិទ្ធិឱ្យនៅឡើយទេ ហេតុដូច្នេះហើយស្ថានភាពដីកសិកម្មរបស់ពួកគាត់នៅតែបន្តស្ថិតនៅក្នុងជម្លោះនៅឡើយ ។



### លោក មាង លីហួរ អ្នកភូមិថ្នល់កែង ខេត្តឧត្តរមានជ័យ៖ អ្នកភូមិមានជម្លោះជាមួយយោធា



ក្នុងខែតុលា ឆ្នាំ២០០៩ ទាហានប្រដាប់ដោយអាវុធបានបណ្តេញពលរដ្ឋ ១១ គ្រួសារចេញពីភូមិថ្នល់កែងដើម្បីធ្វើជាមូលដ្ឋានយោធា។ គ្រួសារទាំងនោះបានទិញដី១៥,៥ហិកតា នៅក្នុងភូមិមួយក្បែរនោះក្នុងឆ្នាំ២០០៨ និងបានពង្រីកដីកសិកម្មរបស់ពួកគាត់ជាបន្តបន្ទាប់រហូតដល់ជាង ៨៥ ហិកតា។ បន្ទាប់ពីការបណ្តេញចេញ គ្រួសារទាំងនោះត្រូវបានផ្តល់ដីលំនៅដ្ឋាននិងដីកសិកម្ម ១ ហិកតាក្នុងមួយគ្រួសារ ទោះបីបានសន្យាថាឱ្យ ៥ហិកតាក្នុងមួយគ្រួសារក៏ដោយ។ ទោះបីជាមានអន្តរាគមន៍ពីអភិបាលស្រុកក្តី ក៏ទាហានទាំងនោះបានបំផ្លាញដំណាំរបស់អ្នកភូមិដោយឈូសឆាយដី និងបានគំរាមកំហែងរកចាប់ខ្លួនឬសម្លាប់ពួកគាត់ប្រសិនបើនៅតែបន្តព្យាយាមធ្វើការដាំដុះលើដីទាំងនោះទៀត។ នៅដើមឆ្នាំ ២០១៦ បន្ទាប់ពីការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋានដើម្បីរកដំណោះស្រាយ អ្នកភូមិសុខចិត្តទទួលយកដីតែពាក់កណ្តាលនៃទំហំដីដែលបានបាត់បង់ទៅ។

### ភូមិពូគង់ ខេត្តមណ្ឌលគិរី ៖ ការកាប់ឈើខុសច្បាប់បង្កដោយក្រុមហ៊ុនបានបំផ្លាញការរស់នៅរបស់ជនជាតិដើមភាគតិច



សហគមន៍ជនជាតិដើមភាគតិចពួង ដែលរស់នៅភូមិពូគង់ស្ថិតក្រោមការគំរាមកំហែងពីការកាប់បំផ្លាញព្រៃឈើនិងការទន្ទ្រានយកដីធ្លី។ នៅក្នុងឆ្នាំ២០១២ ក្រុមហ៊ុន ប៊ិញហ្វឿកក្រចេះរ៉ាប់ប៊ី១ បានចាប់ផ្តើមកាប់ឈើក្នុងតំបន់ព្រៃការពារជុំវិញភូមិពូគង់ ដែលហួសពីការកំណត់ក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។ បន្ទាប់ពីក្រុមហ៊ុនប៊ិញហ្វឿក១ ឈូសឆាយដីប្រហែល ៤.៧៥០ ហិកតា "អ្នកមានអំណាចទាំងនោះ" បានចាប់ផ្តើមកាន់កាប់ដីដែលបានឈូសឆាយហើយ។ បន្ទាប់ពីមានការប៉ុនប៉ងពីសហគមន៍ក្នុងការរារាំងការកាប់ឈើខុសច្បាប់នោះក្នុងខែឧសភា ឆ្នាំ ២០១៣ សន្តិសុខក្រុមហ៊ុនប៊ិញហ្វឿក១ បានមកដល់និងបានបាញ់បំភ័យនៅក្បែរៗសមាជិករបស់សហគមន៍។ សំណាងល្អសហគមន៍បានទទួលការគាំទ្រមួយចំនួនពីអាជ្ញាធរមូលដ្ឋានដែលបានជួយអ្នកភូមិយកដីដែលត្រូវបានគេទន្ទ្រាននោះបានចំនួន ៥០% ត្រឡប់មកវិញហើយកំពុងជួយអ្នកភូមិក្នុងការទប់ស្កាត់ពីការរំលោភយកដីបន្ថែមទៀត ។

### អ្នកភូមិចក់ចារ ខេត្តមណ្ឌលគិរី ៖ ក្រុមហ៊ុនចម្ការកៅស៊ូ គំរាមដល់សហគមន៍ជនជាតិដើមភាគតិច



សហគមន៍ជនជាតិដើមភាគតិច នៅភូមិចក់ចារបានមកតាំងទីលំនៅ នៅតំបន់នេះចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៤០ មកម្លេះ។ ក្នុងឆ្នាំ ២០១១ ក្រុមហ៊ុនវៀតណាមមួយឈ្មោះក្រុមហ៊ុនចម្ការកៅស៊ូវៀតណាមប៊ិញហ្វឿក ១ (Binh Phuoc One) បានទទួលដីសម្បទានសេដ្ឋកិច្ចទំហំ ១០.០០០ ហិកតានៅក្នុងតំបន់នេះ។ ក្រុមហ៊ុននេះ គឺជាបុត្រសម្ព័ន្ធមួយរបស់រដ្ឋដែលគ្រប់គ្រងដោយក្រុមហ៊ុនចម្ការកៅស៊ូវៀតណាម (Vietnam Rubber Group)។ នៅចុងឆ្នាំ ២០១៣ ក្រុមហ៊ុននេះដោយមានការសហការជាមួយកងកម្លាំងប្រដាប់អាវុធ បានចាប់ផ្តើមឈូសឆាយផ្ទៃដីទំហំប្រមាណ ១.០០០ ហិកតា និងរុះរើខ្ទមចាំចំការចំនួន ១៧០ ខ្ទង របស់អ្នកភូមិ។ អ្នកភូមិកំពុងដំណើរការស្នើរសុំប័ណ្ណកម្មសិទ្ធិសមូហភាព ហើយបន្តទាមទារដីរបស់ពួកគាត់ត្រឡប់មកវិញ។ ជាលទ្ធផលអ្នកភូមិជាច្រើនបានប្រឈមមុខនឹងការគំរាមកំហែងនិងការយាយីតាមរយៈប្រព័ន្ធតុលាការ។

### មេភូមិថ្មី ឃុំជ័យឧត្តម ខេត្តរតនគិរី ៖ ក្រុមហ៊ុនវៀតណាម ឈូសឆាយដីរបស់គ្រួសារជនជាតិភាគតិចឡាវ



ដីសម្បទានសេដ្ឋកិច្ចទំហំ ៨.៨២៥ហិកតា គ្រប់គ្រងដោយក្រុមហ៊ុនវៀតណាម ដូនពេញ អាគ្រីកូ (DaunPenh Agrico Company) បានទន្ទ្រានលើដីកសិកម្មរបស់គ្រួសារជនជាតិដើមឡាវចំនួន ១២៥ គ្រួសារនៅក្នុងភូមិថ្មី។ នៅចុងឆ្នាំ ២០១០ គ្រឿងចក្របានចាប់ផ្តើមឈូសឆាយដីកសិកម្មនៅក្បែរភូមិរបស់សហគមន៍ ដើម្បីធ្វើជាចម្ការដូងប្រេង។ ក្រុមហ៊ុនសន្យាថានឹងកសាងផ្លូវ និងប្រព័ន្ធភ្លើងសម្រាប់អ្នកភូមិ តែមិនត្រូវបានធ្វើតាមការសន្យានោះទេ។ អ្នកភូមិ ២២ គ្រួសារដែលមានប័ណ្ណកម្មសិទ្ធិបានទទួលសំណង ប៉ុន្តែគ្រួសារផ្សេងទៀតមិនទទួលបានសំណងអ្វីទាំងអស់។ នៅចុង ឆ្នាំ២០១២ ក្រុមហ៊ុនហ័ងអាញលំផាត់ បានចូលមកគ្រប់គ្រងដីមានជម្លោះ និងបានចាប់ផ្តើមការចរចាជាមួយអ្នកភូមិ។ ការចរចាត្រូវបានបរាជ័យ ហើយគ្រួសារភាគច្រើនបន្តការទាមទារដីរបស់ពួកគាត់ត្រលប់មកវិញ។

### អ្នកភូមិពាក់ ខេត្តរតនគិរី ៖ សហគមន៍ជនជាតិដើមភាគតិចស្វែងរកដំណោះស្រាយជាមួយក្រុមហ៊ុនរ៉ែមាស

ក្រុមហ៊ុនអង្គរហ្គោល (Angkor Gold) មានមូលដ្ឋាននៅប្រទេសកាណាដា បានចាប់ផ្តើមកាប់ឈើ និងខួងរកសំណាករ៉ែមាសនៅក្នុងភូមិពាក់ តាំងពីឆ្នាំ ២០០៩ ដែលបានប៉ះពាល់ដីប្រមាណ ២៨ ហិកតារបស់អ្នកភូមិហើយអ្នកភូមិជំទាស់នឹងប្រតិបត្តិការនោះរហូតដល់ក្រុមហ៊ុនផ្អាកសកម្មភាពរបស់ខ្លួនមួយរយៈ។ បន្ទាប់មកក្រុមហ៊ុនរុករករ៉ែ មេស្កូហ្គោល (Mesco Gold) របស់ឥណ្ឌាបានចុះកិច្ចសន្យាធ្វើអាជីវកម្មរ៉ែមាសនៅក្បែរភូមិនោះនៅក្នុងខែមករា ឆ្នាំ២០១៣។ បន្ទាប់ពីមានការប្រជុំជាច្រើនមកនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៥ អ្នកភូមិបានបង្ហាញដល់ក្រុមហ៊ុននេះពីលក្ខខណ្ឌមួយចំនួនឱ្យសមស្របទៅនឹងអ្វីដែលពួកគេអាចទទួលយកសំណងចំពោះដីដែលពួកគេបានបរិច្ចាគទៅឱ្យក្រុមហ៊ុន។ ក្រុមហ៊ុនរុករករ៉ែមេស្កូហ្គោល (Mesco Gold) បានយល់ព្រមនឹងការទាមទារនេះដោយបានផ្តល់សំណងចំនួន ១៥០០ ដុល្លារក្នុងដីមួយហិកតាដល់គ្រួសារពលរដ្ឋដែលរងផលប៉ះពាល់ផ្តល់ការងារដល់អ្នកភូមិ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន។ សំណងនោះធ្វើឡើងនៅថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៥ ដែលជាឧទាហរណ៍មួយក្នុងការដោះស្រាយជម្លោះដោយវិជ្ជមាន។



### លោក លី ស្រ៊ាខេង៖ គ្រួសារទទួលរងការគំរាមកំហែង និងការវាយប្រហារនៅតំបន់បឹងកក់១ រាជធានីភ្នំពេញ



ក្នុងឆ្នាំ២០០៥ អាជ្ញាធរមូលដ្ឋានបានលក់ដីរបស់គ្រួសារលោកខេងក្នុងសង្កាត់បឹងកក់ទៅឱ្យក្រុមហ៊ុនយុនសៀ អាហារ៍ណនីហារ៍ណ ទោះបីជាក្រុមគ្រួសារគាត់បានរស់នៅលើដីនោះតាំងពីឆ្នាំ១៩៧៩ មកក៏ដោយ។ នៅពេលដែលគ្រួសារនេះមិនព្រមចាកចេញពីដីផ្ទះនោះ ក្រុមហ៊ុនបែរជាបំភិតបំភ័យនិងធ្វើទុក្ខបុកម្នេញតាមផ្លូវតុលាការប្រឆាំងនឹងគ្រួសារលោកជាច្រើនលើកច្រើនសារ។ ក្នុងនោះគេឃើញមានការបោះពស់វែកមានពិសបីក្បាលចូលទៅក្នុងផ្ទះរបស់លោកនៅឆ្នាំ២០១៣។ សមាជិកគ្រួសារនេះត្រូវក្រុមជើងកាងដែលត្រូវបានជួលមកវាយដំយ៉ាងដំណំ ហើយទាំងលោកខេង និងកូនស្រីរបស់លោកត្រូវជាប់ក្នុងពន្ធនាគារក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ក្រោមបទចោទដែលគេបានប្រឌិតឡើង។ កូនស្រីរបស់គាត់ជាប់ពន្ធនាគាររយៈពេល ៥ខែ។ ទោះជាមានការសម្របសម្រួលផ្តល់សំណងឱ្យគ្រួសារនេះជាចុងក្រោយក្នុងខែឧសភា ឆ្នាំ២០១៥ ក៏ដោយក៏លោក ខេង ប្រពន្ធ របស់គាត់ និងកូនស្រីរបស់គាត់ត្រូវបានផ្តន្ទាទោសកាលពីខែមិថុនា ឆ្នាំ២០១៥ ពីបទប្រើប្រាស់ហិង្សាលើម្ចាស់អចលនទ្រព្យ និងត្រូវជាប់ទោសដាក់ពន្ធនាគារចំនួន ៦ខែ តែទោសនោះត្រូវបានព្យួរ។

### អ្នកភូមិថ្មហាលដីក្រហម ខេត្តក្រចេះ ៖ យោធា រួមដៃក្នុងការរំលោភយកដីរបស់ជនជាតិដើមភាគតិច

សហគមន៍ជនជាតិដើមភាគតិចស្មៀង នៅក្នុងភូមិថ្មហាលដីក្រហមបានកាន់កាប់ដីតាំងពីឆ្នាំ១៩៥៣។ ចាប់តាំងពីឆ្នាំ ២០០៦ មក ដីទំហំ ៧៥ ហិកតាដែលប្រជាពលរដ្ឋ ១៥០ គ្រួសារ បានអាស្រ័យផលនោះបានស្ថិតនៅក្រោមការគំរាមកំហែងពីសំណាក់ក្រុមហ៊ុនពាក់ព័ន្ធជាច្រើន។ នៅក្នុងឆ្នាំ២០០៨ ក្រុមហ៊ុនវៀតណាមមួយឈ្មោះក្រុមហ៊ុនហៃយ៉ុងបានចាប់ផ្តើមឈូសឆាយដីកសិកម្មរបស់អ្នកភូមិដើម្បីធ្វើជាចម្ការកៅស៊ូ។ ជាការឆ្លើយតបនឹងការតវ៉ារបស់អ្នកភូមិកងកម្លាំងប្រដាប់ដោយអាវុធត្រូវបានយកមកដាក់ពង្រាយដើម្បីល្បាតនៅបរិវេណដីមានជម្លោះនោះហើយបានបាញ់ព្រមានទៅលើអ្នកភូមិដែលប៉ុនប៉ងចូលទៅកាន់ដីនោះ។ ក្រុមហ៊ុនហៃយ៉ុង ទទួលបានសម្បទានដីសេដ្ឋកិច្ចទំហំ ៧០១ ហិកតា ក្នុងឆ្នាំ២០០៧ ហើយក្រោយមក ដីទំហំ ៤៣ ហិកតាត្រូវបានកាត់ចេញក្នុងឆ្នាំ២០១២។ ថ្វីត្បិតតែមានការដាក់ពាក្យបណ្តឹងមួយចំនួនទៅអាជ្ញាធរជាប់ពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗក៏ដោយក៏មិនទាន់មានដំណោះស្រាយណាមួយនៅឡើយទេ ហើយអ្នកភូមិនៅតែបន្តធ្វើការតស៊ូដើម្បីទទួលបានដីត្រឡប់មកវិញ។



### ភូមិចឹង ខេត្តក្រចេះ ៖ មន្ត្រីមានអំណាចរំលោភយកដីពីអ្នកភូមិជនជាតិដើមភាគតិច



ជនជាតិដើមភាគតិចពួងបានរស់នៅលើដីរបស់ពួកគាត់ដែលមានទីតាំងនៅ ភូមិចឹងឃុំឃ្សឹម ស្រុកស្នួលតាំងពីយូយារណាស់មកហើយ។ សហគមន៍បានលើកឡើងថាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ អ្នកមានអំណាចដែលមានខ្នងក្រាស់រួមមានទាំងមន្ត្រីឋានៈខ្ពស់គឺឯកឧត្តម ឡេង អន ផងដែរនោះបានរំលោភយកដីប្រមាណ ៣.០៣៨ ហិកតា ដែលប្រជាពលរដ្ឋ ១៥០ គ្រួសារអាស្រ័យផល។ មានអ្នកចំណូលថ្មីជាច្រើនបានចូលមកតាំងទីលំនៅនៅលើដីនោះហើយក៏មានគ្រួសារជនជាតិដើមភាគតិចមួយចំនួនបានលក់ដីផ្ទាល់ខ្លួនរបស់ពួកគាត់ផងដែរ។ ជាងនេះទៅទៀតដីនោះបានក្លាយជាកន្លែងកាប់ឈើខុសច្បាប់ដ៏ធំ។ ហេតុនេះហើយសហគមន៍បានបាត់បង់ដីបុព្វបុរសរបស់ខ្លួនអស់ជាច្រើន ទោះបីជាមានការជំទាស់តវ៉ានិងការដាក់ពាក្យបណ្តឹងជាច្រើនយ៉ាងណាក៏ដោយ។

### លោក សោម សុវណ្ណនី អ្នកភូមិក្រចេះ៖ ដីលំនៅឋានរបស់ពលរដ្ឋ កំពុងជួបប្រទះហានិភ័យ ដោយសារគម្រោងសាងសង់សាកលវិទ្យាល័យនៅខេត្តក្រចេះ



ប្រជាពលរដ្ឋចំនួន ២៣ គ្រួសារនៅភូមិស្រែស្តៅ បារម្ភក្រែងដីរបស់ពួកគាត់ដែលបានកាន់កាប់ច្រើនជំនាន់ហើយនោះនឹងត្រូវគេរឹបអូសយក ក្នុងគម្រោងផ្លាស់ប្តូរព្រលានយន្តហោះដែលមិនបានប្រើការយកទៅសាងសង់សាកលវិទ្យាល័យកសិកម្ម។ រដ្ឋាភិបាលបានផ្តល់ទីតាំងផ្លាស់ប្តូរលំនៅថ្មីមួយដល់អ្នកភូមិ នៅក្នុងព្រៃដាច់ស្រយាលមួយប៉ុន្តែទីតាំងនោះមិនសមស្របសម្រាប់ការដាំដំណាំផ្សេងៗនោះទេ។ អ្នកភូមិបានបដិសេធក្នុងការចាកចេញ។ បន្ទាប់ពីការខ្នះខ្នែងធ្វើយុទ្ធនាការរបស់គ្រួសារទាំងឡាយនោះ នៅខែមិថុនា ២០១៤ អាជ្ញាធរមូលដ្ឋានបានយល់ព្រមអភិវឌ្ឍន៍មិនឱ្យហួសពីព្រំប្រទល់ព្រលានយន្តហោះចាស់នោះទេ។ ក៏ប៉ុន្តែគ្រួសារទាំងនោះក៏នៅមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីរបស់ពួកគាត់ដែលធ្វើឱ្យពួកគាត់ពុំមានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីនោះឡើយ។

### ប្រជាពលរដ្ឋក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគិរី ៖ ចម្ការកៅស៊ូបានបង្ខំសហគមន៍ជនជាតិដើមភាគតិចឱ្យបោះបង់ដី



នៅក្នុងឃុំប៊ូស្រា ប្រជាពលរដ្ឋចំនួន ៧៨៨ គ្រួសារដែលភាគច្រើនជាជនជាតិដើមភាគតិចបានរងផលប៉ះពាល់ដោយសារសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនសុកហ្វីន ខេស៊ីឌី (Socfin-KCD)ដើម្បីដាំកៅស៊ូ។ ក្រុមហ៊ុននេះបានឈូសឆាយដីរបស់អ្នកភូមិនៅឆ្នាំ២០០៨។ អ្នកភូមិបានដាក់ពាក្យបណ្តឹងជាច្រើនទៅអាជ្ញាធរពាក់ព័ន្ធ ប៉ុន្តែពួកគេនៅមិនទាន់បានទទួលសំណងសមរម្យណាមួយចំពោះដីដែលបានបាត់បង់នោះឡើយ។ ជម្លោះដីធ្លីនោះកាន់តែមានសភាពធ្ងន់ធ្ងរដោយសារសេចក្តីសម្រេចរបស់រដ្ឋាភិបាល ដែលបានផ្តល់សម្បទានដីសង្គមកិច្ចឱ្យប្រជាពលរដ្ឋដែលមកពីខេត្តផ្សេងៗនៅលើដីក្បែរភូមិនោះទៀតដែលបានរំលោភទៅលើដីចម្ការ និងដីបញ្ចុះសពរបស់អ្នកភូមិ។ មានគ្រួសារជាច្រើនបានទទួលការដាក់សម្ពាធពីអាជ្ញាធរមូលដ្ឋានឱ្យទទួលយកកម្មសិទ្ធិដីឯកជន។ គ្រួសារដែលនៅសេសសល់ទាំងប៉ុន្មានបានបន្តទាមទារប្លង់កម្មសិទ្ធិសមូហភាពដែលពួកគេបានស្នើសុំតាំងពីឆ្នាំ ២០១២។

ឧបត្ថម្ភគាំទ្រដោយ

diakonia
PEOPLE CHANGING THE WORLD

Sida

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរសព្ទលេខ ៖ + ៨៥៥ (០) ២៣ ៧២៦ ៩០១ អ៊ីម៉ែល ៖ infor@cchrcambodia.org
ទូរសារលេខ ៖ + ៨៥៥ (០) ២៣ ៧២៦ ៩០២ គេហទំព័រ ៖ www.cchrcambodia.org

CC BY NC SA

